# ករណីសិក្សាៈ
# សៀវភៅពលកម្មសម្រាប់សាងសង់លំនៅដ្ឋានខូចខាតដោយសារសង្គ្រាម
# នៅប្រទេសតាជីគីស្ថាន ( Tajikistan )

## គម្រោងកម្មវិធីរបស់អង្គការសហព័ន្ធសង្គ្រោះកុមារ ( SCF PROGRAM )

**១-** បន្ទាប់ពីការដួលរលំនៃសហភាពសូវៀតមក ការវាយប្រយុទ្ធគ្នាដើម្បីដណ្តើមអំណាចដឹកនាំក៏បានចាប់ផ្តើម ឡើងនៅក្នុងសហព័ន្ធ តាជីគីស្ថាន (Tajikistan) នៃអតីតសហភាពសូវៀត រវាងពួកកុម្មុយនីស្ត និងពួកសម្ព័ន្ធមិត្ត *(ប្រឆាំងកុម្មុយនីស្ត និងក្រុមប្រឆាំងអ៊ីស្លាមនិយម)*។ លទ្ធផលសង្គ្រាមស៊ីវិលដ៏ឃោរឃៅ កើតឡើងនៅដើមឆ្នាំ ១៩៩១ ហើយដែលរីករាលដាលពីរដ្ឋធានី ឌុហ្សានបេ (Dushanbe) ទៅដល់តំបន់ជនបទនានាទូទាំងប្រទេស។ សង្គ្រាមនេះបានបន្តរហូតដល់ខែធ្នូ ឆ្នាំ១៩៩២។ នៅតាមភូមិនានា ទំនាស់នយោបាយនេះ នៅតែមានភាពមិនច្បាស់លាស់ ដូច្នេះវាហាក់បីដូចជាទំនាស់អំពីជាតិសាសន៍ រវាងជនជាតិ កុលីយ៉ាប៊ី (Kulyabi Tajiks) ដែលគាំទ្រពួកកុម្មុយនីស្ត និងជនជាតិហ្គាមី (Garmi Tajiks) ដែលបានភ្ជាប់ខ្លួនជាមួយក្រុមប្រឆាំង។ ជនជាតិកុលីយ៉ាប៊ី (Kulyabi) និងហ្គាមី (Garmi) ជាជនជាតិភាគតិច តាជីក (Tajiks) ដែលមានសាសនាដូចគ្នា ទំនៀមទំលាប់ប្រពៃណី និង ភាសាតែមួយ គឺភាសា ហ្វាស៊ី (Farsi)។

**២-** ការប្រយុទ្ធគ្នាដ៏ខ្លាំងក្លាបានកើតឡើងនៅខេត្ត **ខេតឡុន** (Khatlon) ស្ថិតនៅភាគនិរតីនៃប្រទេស **តាជីគីស្ថាន** (Tajikistan) និងជាប់ព្រំប្រទល់ប្រទេស**អាហ្វហ្គានីស្ថាន** (Afghanistan)។ តំបន់នេះត្រូវបានគេមករស់នៅតាំងពីទស្សវត្សរ៍ឆ្នាំ១៩៣០ និង ឆ្នាំ១៩៤០ ដែលពេលនោះរដ្ឋាភិបាលសូវៀត បានបង្ខំឱ្យជនជាតិ **ហ្គាមី** និង **កុលយ៉ាប៊ី**រាប់សែននាក់ផ្លាស់ប្តូរទីលំនៅមករស់នៅតំបន់នេះ ដើម្បីធ្វើជាកម្មករចំការកប្បាសរបស់រដ្ឋ ដែលទើបតែបង្កើតថ្មី។ ភូមិទាំងមូលត្រូវបានគេផ្លាស់ប្តូរទីតាំង ហើយតំបន់ទាំងមូលបានក្លាយជាភូមិដែលមានជនជាតិតែមួយ។ ប៉ុន្តែជាច្រើនឆ្នាំក្រោយមក ភូមិខ្លះគេបានដាក់ជនជាតិទាំងពីរបញ្ចូលគ្នា ។ នៅពេលសង្គ្រាមស៊ីវិលកើតឡើង អ្នកភូមិប្រហែល ១/៤ នៃប្រជាជនក្នុងតំបន់នេះ ត្រូវបានគេដាក់ឲ្យរស់នៅលាយឡំគ្នា ។ នៅតាមទីក្រុង និងទីប្រជុំជន ការរៀបការរវាងជនជាតិមួយទៅនឹងជនជាតិមួយទៀតមានកម្រិតខ្ពស់។ ការសំដែងចេញនូវអត្តសញ្ញាណដ៏ខ្ជាប់ខ្ជួនរបស់ជនជាតិនីមួយៗ ក៏មិនសូវមានដែរ ក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

**៣-** នៅក្នុងពេលសង្គ្រាម ភូមិទាំងឡាយបានក្លាយជាគោលដៅសម្រាប់គេលួចប្លន់ និងដុតបំផ្លាញដោយ ភាគីទាំងសងខាង ។ នៅចុងឆ្នាំ ១៩៩២ ដោយមានការជួយពីកងទ័ពរុស្ស៊ី ដែលឈរជើងនៅក្នុងតំបន់នោះ កងកម្លាំងរបស់**កុលីយ៉ាប៊ី** (Kulyabi) បានវាយកំចាត់ជនជាតិ **ហ្គាមី** (Garmi) ឱ្យរត់ខ្ចាត់ខ្ចាយអស់។ ការខូចខាតក្នុងពេលសង្គ្រាមមិនធ្ងន់ធ្ងរប៉ុន្មានទេ តែបន្ទាប់ពីទទួលបានជ័យជំនះ កងជីវពល**កុលីយ៉ាប៊ី** (Kulyabi) នៅតែខឹងសម្បារយ៉ាងខ្លាំង ហើយបានដុតបំផ្លាញផ្ទះសម្បែង និងភូមិរបស់ជនជាតិ**ហ្គាមី** (Garmi) គ្មានសល់។ បុរសជាច្រើនត្រូវបានគេសម្លាប់ លំនៅដ្ឋានជាង ២០.០០០ ខ្នងត្រូវបានខូចខាត និងរងការបំផ្លាញយ៉ាងធ្ងន់ធ្ងរ ហើយមានគ្រួសារជាច្រើនបានរត់

គេចខ្លួនដើម្បីសុវត្ថិភាព។ មានតែព្រះវិហារអ៊ីស្លាមក្នុងភូមិ របស់ជនជាតិហ្គាមី (Garmi) ទេ ដែលមិនត្រូវបានគេដុតបំផ្លាញ។

**៤-** ថ្វីត្បិតតែការច្បាំងគ្នាដ៏ចំហរនេះបានបញ្ចប់ទៅវិញនៅចុងឆ្នាំ១៩៩២ ក៏ដោយ ក៏ក្រុមប្រឆាំងប្រដាប់អាវុធ នៅតែបន្តសកម្មភាពនៅប៉ែកខាងជើងជាប់ព្រំដែនប្រទេស**អាហ្វហ្គានីស្ថាន** (Afghanistan) ដដែល ហើយពួកគេបន្តឆ្លងព្រំដែនមកធ្វើការវាយប្រហារជាញឹកញាប់។ លើសពីនេះទៀត ពួកគេបានត្រួតត្រាលើតំបន់ជួរភ្នំមួយចំនួននៃប្រទេស**តាជីគីស្ថាន**(Tajikistan) ផងដែរ។ ទាហានរុស្សីចំនួន ២៥.០០០នាក់ ត្រូវបានរក្សាទុកនៅក្នុងប្រទេសនេះ ដើម្បីជួយរក្សាការពារមិនឲ្យការច្បាំងគ្នាដ៏ចំហរនេះកើតឡើងសារជាថ្មី។ ទោះជាយ៉ាងនេះក្តី ក៏បរិយាកាសនៃភាពគ្មានច្បាប់ទំលាប់នៅតែបន្ត ដោយសារតែមានក្រុមប្រដាប់អាវុធនានា បានប្រព្រឹត្តនូវឧក្រិដ្ឋកម្ម (ពេលខ្លះមានចំរុះជាតិសាសន៍) បន្តការលួចប្លន់អ្នកភូមិ និង លួចយកជំនួយមនុស្សធម៌ទៀតផង។

**៥- តាជីគីស្ថាន** (Tajikistan) គឺជាតំបន់ក្រីក្រជាងគេរបស់សហភាពសូវៀត ។ អាជ្ញាធរមជ្ឈឹមសូវៀត បានសម្រេចឲ្យសេដ្ឋកិច្ច**តាជីគីស្ថាន** (Tajikistan) ផ្តោតលើផលិតផលកប្បាស និងសហគ្រាសកប្បាស (ដូចជាបង្កើតរោងចក្រកប្បាស ផលិតគ្រាប់ពូជកប្បាស និងការកាត់ដេរសំលៀកបំពាក់)។ ក៏ដូចជាសហព័ន្ធដ៏ទៃទៀតនៃសហភាពសូវៀតដែរ **តាជីគីស្ថាន**(Tajikistan) ត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើការធ្វើពាណិជ្ជកម្មដែលនាំចូលពីខាងក្រៅ។ គ្រឿងឧបភោគបរិភោគសំខាន់ៗ មួយចំនួនត្រូវបាននាំចូលពីបរទេសតាំងពីទសវត្សរ៍ឆ្នាំ១៩៣០។

**៦-** ចំការកប្បាសក្នុងខេត្ត **ខេតឡុន**(Khatlon) ត្រូវបានរៀបចំឲ្យទៅជាកសិដ្ឋានដ៏ធំរបស់រដ្ឋ ដែលគ្របណ្តប់ផ្ទៃដីដាំដំណាំស្ទើតែទាំងអស់ក្នុងខេត្តនេះ ហើយបានផ្តល់ការងារដល់ពលរដ្ឋភាគច្រើនដែលមានលទ្ធភាពធ្វើការងារ។ នៅគ្រប់ចំការកប្បាសរដ្ឋនីមួយៗ គ្របដណ្តប់លើភូមិជាច្រើន ដោយមិនរើសអើង ឬប្រកាន់ជនជាតិឡើយ ដូច្នេះជនជាតិ**កុលីយ៉ាប៊ី**(Kulyabi) និង**ហ្គាមី**(Gami) បានធ្វើការជាមួយគ្នា។ បុរសៗទទួលខុសត្រូវក្នុងការចាត់ចែង និងថែទាំប្រឡាយទឹក ហើយស្ត្រីៗដាំដុះ ធ្វើចំការ និងប្រមូលផល។ អ្នកភូមិប្រើប្រាស់សាលារៀន មន្ទីរពេទ្យ និងសេវាសង្គមផ្សេងៗទៀតរួមគ្នា តាមប្រព័ន្ធរបស់សហភាពសូវៀត។ ថ្វីបើមានភាពតានតឹង និងការប្រកួតប្រជែងដើម្បីតំណែងដឹកនាំក្នុងកសិដ្ឋានរដ្ឋទាំងនោះក៏ដោយ ក៏ទំនាក់ទំនងរវាងក្រុមទាំងនោះនៅតែល្អជាមួយគ្នា។

**៧-** ផលិតផលកប្បាសធ្លាក់ចុះទាំងស្រុងនៅអំឡុងឆ្នាំ ១៩៨០។ សង្គ្រាមបានធ្វើឲ្យស្ថានភាពសេដ្ឋកិច្ចកាន់តែដុនដាបឡើងៗ ។ រោងចក្រ ឧបករណ៍ និង ប្រព័ន្ធធារាសាស្រ្តសំខាន់ៗ សម្រាប់ការផលិតកប្បាសត្រូវបានបំផ្លាញ រួមទាំងការចាកចេញនៃអ្នកជំនាញបច្ចេកទេសបរទេសដែលមិនមែនជាជនជាតិតាជីគីស្ថាន និង អ្នកគ្រប់គ្រងបរទេសជាច្រើននាក់ផងដែរនោះ បានធ្វើឱ្យសេដ្ឋកិច្ចប្រទេសនេះធ្លាក់ចុះដុនដាប។ ការធ្លាក់ចុះផ្នែកពាណិជ្ជកម្មបានបន្សល់ទុកឲ្យប្រទេស **តាជីគីស្ថាន** ជួបប្រទះការខ្វះខាតស្បៀងអាហារយ៉ាងធ្ងន់ធ្ងរ។

**៨-** នៅពេលសង្គ្រាមបានបញ្ចប់ ដីចំការទុកទំនេរចោល រង់ចាំដំណាំកប្បាសមកដាំឡើងវិញ ដែលនេះជាមុខរបររបស់ប្រជាជនក្នុងខេត្ត **ខេតឡុន**(Khatlon) ពឹងផ្អែកទាំងស្រុងដើម្បីរស់នៅ។ ប្រព័ន្ធធារាសាស្រ្តមួយចំនួនត្រូវបានបំផ្លាញ ធ្វើឲ្យអន្តរាយដល់សក្តានុពលនៃដំណាំកប្បាស និងលទ្ធភាពទទួលបានទឹកប្រើប្រាស់ក្នុងភូមិផងដែរ។

**៩**- គ្រួសារនីមួយៗនៅក្នុងខេត្ត **ខេតឡុន**(Khatlon) នៅមានដីឯកជនតូចល្មម ដែលពួកគេតែងតែដាំដំណាំ សម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ និងលក់ដូរបន្តិចបន្តួចក្នុងស្រុក។

**១០**- ប្រជាជនក្នុងខេត្ត **ខេតឡុន**(Khatlon) បានផ្តួចផ្តើមគំនិតក្នុងការផ្សះផ្សារ ក្នុងកំឡុងពេលធ្វើមាតុភូមិនិវត្តន៍របស់ជនជាតិ**ហ្គាមី** (Garmi) ។ ឧទាៈ ស្ត្រីជាមន្ត្រីរដ្ឋាភិបាលថ្នាក់ស្រុកម្នាក់បានឲ្យដឹងថា អតីតអ្នកជិតខាងរបស់អ្នកស្រី ជាជនជាតិ **ហ្គាមី** (Garmi) បានត្រឡប់មកវិញ អ្នកស្រីបានរៀបចំម្ហូបអាហាររយៈពេល៣ថ្ងៃ ហើយបានអញ្ជើញអ្នកធ្វើមាតុភូមិនិវត្តន៍ទាំងនោះ និងជនជាតិ**កុលីយ៉ាប៊ី** (Kulyabi) ដែលជាអ្នកជិតខាងរបស់គាត់មកពិសារអាហារពេលល្ងាចជាមួយគ្នា ក្រោមទ្រើងផ្កាក្នុងសួនច្បាររបស់គាត់ ។ នៅក្នុងភូមិផ្សេងទៀត ពេលដែលជនជាតិ**ហ្គាមី** (Garmi) វិលត្រឡប់មកវិញ ជនជាតិ**កុលីយ៉ាប៊ី** (Kulyabi) នាំគ្នាចេញទៅជួប ដោយមានចែកនំប៉័ង និងអំបិលដែលជានិមិត្តរូបនៃទំនៀមទំលាប់ប្រពៃណីក្នុងការស្វាគមន៍គ្នា។

**១១**- មនុស្សជាច្រើនកត់សំគាល់ថាស្ត្រីមានតួនាទីយ៉ាងសំខាន់ ក្នុងការយកជ័យជំនះលើការគុំគួន។ ដូចដែលស្ត្រីម្នាក់បាននិយាយថា ធម្មជាតិរបស់ស្ត្រីខុសគ្នាពីបុរស។ ស្ត្រីអាចបំភ្លេច និងអភ័យទោស ប៉ុន្តែបុរសមានភាពសាហាវបន្តិច ឈាមរបស់គាត់ក្តៅ ។ អ្នកខ្លះបានបង្ហាញថា អ្វីៗដែលស្ត្រីអាចធ្វើបានដូចជា៖

- ស្ត្រីជនជាតិ **កុលីយ៉ាប៊ី** Kulyabi និយាយថា៖ អប់រំកូនមិនឲ្យស្អប់ខ្ពើម
- ស្ត្រីជនជាតិ **ហ្គាមី** Garmi និយាយថា៖ បង្រៀនកូនចៅរបស់ខ្ញុំ កុំឲ្យមានការសងសឹក កុំឲ្យរំលឹករឿងរ៉ាវឡើងវិញ និងលេងល្បែងសង្គ្រាមជាមួយពួកគេ
- ស្ត្រីជនជាតិ **កុលីយ៉ាប៊ី** Kulyabi និយាយថា៖ " ធ្វើការក្នុងគំរោងតែមួយជាមួយគ្នា"
- ស្ត្រីជនជាតិ **ហ្គាមី** Garmi និយាយថា៖ "ឲ្យប្តីរបស់ខ្ញុំដែលជាអតីតគ្រូបង្រៀនជួបជាមួយក្រុមគ្រូបង្រៀនរបស់គាត់ ដើម្បីជជែកពិភាក្សាគ្នាថាតើ គ្រូបង្រៀនទាំងពីរក្រុមនេះធ្វើយ៉ាងណាដើម្បីបង្រៀនក្មេងៗឲ្យមានចរិកល្អក្នុងសាលារៀន និង
- បុរសជនជាតិ **កុលីយ៉ាប៊ី** Kulyabi និយាយថា៖ ស្ត្រីត្រូវតែដឹកនាំយើង

**១២**- នៅក្នុងភូមិខ្លះ ស្ត្រី និងបុរសចំណាស់ៗនាំគ្នាបង្កើតគណៈកម្មការដើម្បីជួយដោះស្រាយទំនាស់អំពីលំនៅដ្ឋាននៅពេលដែលជនជាតិ**ហ្គាមី**(Garmi) វិលត្រឡប់មកវិញ និងបានឃើញថាផ្ទះរបស់ពួកគាត់ពីមុន ត្រូវបានរស់នៅដោយជនជាតិ **កុលីយ៉ាប៊ី** (Kulyabi) ។ ទោះជាយ៉ាងនេះក៏ដោយ មានប្រជាជនជាច្រើនមានទំនួលខុសត្រូវក្នុងការកសាងសន្តិភាពនៅតាមកន្លែងផ្សេងទៀតផងដែរ។ ពួកគេជឿជាក់ថា ៖ *"ពេលវេលាគឺជាឱសថទិព្វ"* ឬ *"សង្គ្រាមនឹងមិនកើតឡើងម្តងទៀតទេ ដោយមនុស្សមិនចង់បានសង្គ្រាម"* ឬ *"យើងបានរៀនមេរៀនរបស់យើង"* ឬ *"ពួកគេបានរៀនពីមេរៀនរបស់ពួកគេហើយ"*។

**១៣**- នៅឆ្នាំ១៩៩៤ សហព័ន្ធសង្គ្រោះកុមារ (Save the Children Federation - SCF) មានគម្រោងកម្មវិធីមួយដ៏ធំ និងយ៉ាងសកម្ម ក្នុងស្រុកមួយចំនួននៃខេត្ត**ខេតឡុន** (Khatlon)។ គម្រោងនេះបានផ្តល់ជាស្បៀងពលកម្ម ដល់ក្រុមពលករដែលជាប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈកម្មវិធីស្បៀងពលកម្ម (Food For Work, FFW) ដែលវាជាការ

ដោះដូរទៅនឹងកំលាំងពលកម្មរបស់ពួកគេ ក្នុងការសាងសង់លំនៅដ្ឋានឡើងវិញ ដែលខូចខាតដោយសារសង្គ្រាម។ គម្រោងនេះទទួលបានជោគជ័យក្នុងការគាំទ្រឲ្យមានការសាងសង់លំនៅដ្ឋានឡើងវិញជាច្រើនខ្នង ហើយជំរុញឲ្យប្រជាពលរដ្ឋ ដែលរត់គេចខ្លួនពេលមានសង្គ្រាមធ្វើមាតុភូមិនិវត្តន៍មកកាន់លំនៅដ្ឋានវិញ។ បុគ្គលិករបស់សហព័ន្ធសង្គ្រោះកុមារ (SCF) គិតថា ការធ្វើមាតុភូមិនិវត្តន៍ គឺជាជំហានដំបូងក្នុងការផ្សះផ្សារជាតិ ប៉ុន្តែពួកគេក៏ចង់រកឱកាសផ្សេងទៀត ដើម្បីប្រើប្រាស់កម្មវិធីនេះក្នុងការជំរុញឲ្យមានទំនាក់ទំនង និងការផ្សះផ្សារ រវាងក្រុមជនជាតិទាំងនោះ។

**១៤-** នៅដើមដំបូងនៃការធ្វើមាតុភូមិនិវត្តន៍ សហព័ន្ធសង្គ្រោះកុមារ (SCF) បានកំណត់បញ្ហាធំៗ២ ក្នុងប្រទេស **តាជីគីស្ថាន** (Tajikistan) ក្រោយពីសង្គ្រាម៖ នោះគឺការខ្វះខាតម្ហូបអាហារ និងការខូតខាតលំនៅដ្ឋានដ៏ច្រើនលើសលប់ ។ ទោះបីជាបញ្ហាសន្តិសុខស្បៀងមិនមានគ្រប់គ្រាន់នៅក្នុងភូមិរបស់ជនជាតិកុលីយ៉ាប៊ី (Kulyabi) ក៏ដោយ ក៏បញ្ហាកង្វះអាហារូបត្ថម្ភ ត្រូវបានគេរកឃើញថា កើតមាននៅតាមភូមិដែលបានបំផ្លិចបំផ្លាញ។

**១៥-** ដំណោះស្រាយរបស់សហព័ន្ធសង្គ្រោះកុមារ (SCF) គឺបង្កើតឲ្យមានក្រុមនៅតាមភូមិនីមួយៗ ដែលត្រូវបានទទួលស្បៀងពលកម្មដើម្បីសាងសង់ និងជួសជុលលំនៅដ្ឋានឡើងវិញ។ អាទិភាពត្រូវបានផ្តល់ឲ្យទៅតាមភូមិដែលមានការខូតខាតច្រើន ហើយរាល់ផ្ទះសម្បែងដែលខូចខាតក្នុងភូមិគោលដៅ គឺអាចទទួលបានការសាងសង់ឡើងវិញ។ ប្រជាជនក្នុងភូមិទាំងអស់ (បុរស និងស្ត្រី) ដែលចង់ធ្វើការងារសាងសង់ គឺមានសិទ្ធិចូលរួមក្នុងក្រុម។ សហព័ន្ធសង្គ្រោះកុមារ (SCF) ធ្វើសម្រង់ព័ត៌មានអំពីផ្ទះសម្បែង ដើម្បីផ្តល់អាទិភាពសម្រាប់ការជួសជុល ហើយធ្វើ "កិច្ចសន្យា" ជាមួយក្រុមសាងសង់ដើម្បីធ្វើការជួសជុល។ ក្រុមនេះបានសាងសង់ផ្ទះ តាមបែបប្រពៃណីដោយប្រើដីភក់ក្នុងមូលដ្ឋានធ្វើជាឥដ្ឋជញ្ជាំង ហើយសហព័ន្ធសង្គ្រោះកុមារ ផ្តល់គ្រឿងប្រក់ដំបូល (អំណោយរបស់ UNHCR ដែលជំនួយទាំងនេះជាផ្នែកមួយនៃកម្មវិធីមាតុភូមិនិវត្តន៍ជនភៀសខ្លួន)។ ស្បៀងដែលមនុស្សម្នាក់ទទួលបានក្នុងក្រុមសាងសង់ គឺគ្រប់គ្រាន់ដើម្បីបង្គ្រប់បាន ៨០ ភាគរយ នៃកាល់ឡូរីជាមធ្យម សំរាប់តំរូវការគ្រួសារនៅក្នុងរដូវរងារនាឆ្នាំ១៩៩៤-១៩៩៥។

**១៦-** នៅសិរទរដូវឆ្នាំ១៩៩៤ កម្មវិធីស្បៀងពលកម្មបានបង្កើតឡើង និងមានសកម្មភាពយ៉ាងផុសផុលក្នុងស្រុកជាច្រើននៃខេត្ត **ខេតឡុន** (Khatlon)។ កម្មវិធីនេះបានជួលបុគ្គលិកក្នុងស្រុកចំនួន៨០នាក់ ហើយកម្មវិធីនេះបានជួយដល់ប្រជាពលរដ្ឋចំនួន ១៥.០០០នាក់ ភាគច្រើនជាជនភៀសខ្លួន ដោយសាងសង់ផ្ទះចំនួន ១២.០០០ខ្នង។ ដើម្បីធានាមិនឲ្យមានភាពរើសអើងលើជនជាតិភាគតិចក្នុងការជួលជាបុគ្គលិកនោះ សហព័ន្ធសង្គ្រោះកុមារ (SCF) បានរៀបចំឱ្យមានការសំភាសន៍ ដោយមានបុគ្គលិកដែលមានជាតិសាសន៍ផ្សេងៗគ្នាបានចូលរួមក្នុងការសម្ភាសន៍បេក្ខជននីមួយៗ។ ការសំភាសន៍នេះ ត្រូវបានសន្មត់ថា បើមានជនជាតិភាគតិចណា និយាយបង្ខូច ឬ មានភាពលំអៀងលើជនជាតិមួយផ្សេងទៀតនោះ នឹងត្រូវបានកត់សំគាល់ដោយអ្នកសំភាសន៍ណាម្នាក់ក្នុងចំណោមអ្នកសំភាសន៍ទាំងនោះ។ សហព័ន្ធសង្គ្រោះកុមារ (SCF) បានពេញចិត្ត ដោយសារពួកគេអាចធ្វើឲ្យការធ្វើមាតុភូមិនិវត្តន៍បានលឿន មានសុវត្ថិភាពដល់ជនភៀសខ្លួន និងជនភៀសសឹកក្នុងស្រុក នោះហើយជាអ្វីដែលគេត្រូវធ្វើដំបូងគេ មុននឹងធ្វើការផ្សះផ្សារ។